ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣២

ចុះថ្ងៃទី១៩ខែមករាឆ្នាំ២០០៤

# នាមនាមប្រជារាស្ត្រខ្មែរ

## សាលដីកា

តុលាការកំពូល

លេខ : ៣០៧

ចុះថ្ងៃទី០៩ខែធ្នូឆ្នាំ២០០៥ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥

ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឃឹម ប៉ុណ្ណ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោក វៀល មួន ជាចៅក្រម

៣-លោក ស៊ិន ឌឹម ជាចៅក្រម

៤-លោក ឈឹម ស៊ីផល ជាចៅក្រម

៥-លោក សោម សិរីវឌ្ឍ ជាចៅក្រម

៦-លោក យស់ សូខឿន ជាចៅក្រមរបាយការណ៍

៧-លោក ប៉ែន សាវឿន ជាចៅក្រម

៨-លោក គង់ ភីរុន ជាចៅក្រម

៩-លោក ម៉ុង មុន្នីចរិយា ជាចៅក្រម

**ក្រឡាបញ្ជី**

អ្នកស្រី ឃុត សុគន្ធា

**តំណាងមហាអយ្យការ**

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីកាលេខ ៩៦"ក"ចុះថ្ងៃទី ១២-៦-២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦៤ ចុះថ្ងៃទី ១២-៨-២០០២ របស់សាលាឧទ្ធរណ៍។

រវាងដើមចោទឈ្មោះ **ទឹម ចារិទ្ធ** "ជាចុងបណ្តឹងសាទុក្ខលើកទី២"អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរកងរាជអាវុធហត្ថ ទីលំនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពន់ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

**មេធាវី : លោក ធាត់ សៀកឈី**

និង ចុងចម្លើយឈ្មោះ **កេត សាន់ណា** "ជាដើមបណ្តឹងសាទុក្ខលើកទី២" ភេទស្រី អាយុ ៤១ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ទីលំនៅ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពន់ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

**មេធាវី** : លោក កែម យាំ

**កម្មវត្ថុបណ្តឹង** : ប្តឹងសុំសិទ្ធិកាន់កាប់ដី

តាមបណ្តឹងសាទុក្ខលើកទី២លេខ ២៩៣ ចុះថ្ងៃទី ២៤-៦-២០០៣ របស់អ្នកស្រី កេត ផាន់ណា ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៩៦"ត" ចុះថ្ងៃទី ១២-៦-២០០៣ របស់ សាលាឧទ្ធរណ៍ត្រង់ចំណុចទី ២ នៃ សេចក្តីសំរេច ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣២ ចុះថ្ងៃទី ១៩-០១-២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ១៨-០២-២០០០ របស់ដើមចោទលោក ហ៊ុយ ហ៊ាង ថា ខ្លួនសុំសិទ្ធិកាន់កាប់ និង គ្រប់គ្រងដីធ្លី ស្ថិតនៅភូមិទី ៩ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពន់ ខ័ណ្ឌមានជ័យ ព្រំប្រទល់ខាងជើងទល់នឹងអូរ ខាងត្បូងទល់នឹងថ្នល់ ខាងកើតទល់នឹងឈ្មោះ គួយ គុណ ខាងលិចទល់នឹងដី សារឿន ដោយសំអាងហេតុថា ដីនេះចាប់ពីឆ្នាំ ១៩៨៣ រហូតមកដល់បច្ចុប្បន្ននេះឈ្មោះ ឃឹម ផង់ បានកាន់កាប់ និង រស់នៅរហូតមកដោយមានបង្កាន់ដៃកាន់កាប់លេខ ៤៥៩០ ចុះថ្ងៃទី ១៦-០១-១៩៩០ និងស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី ០៨-១១-៨៩ ដោយមានការទទួលស្គាល់ពីរដ្ឋអំណាចមូលដ្ឋានត្រឹមត្រូវ ។ មកដល់ថ្ងៃទី ០៤-៨-៩៩ ខ្លួនបានទិញដីនេះពីឈ្មោះ ឃឹម ផង់ មានសំបុត្រលក់-ទិញ ដោយមានចុះហត្ថលេខាបញ្ជាក់ពីមេភូមិ និង សង្កាត់ត្រឹមត្រូវទៀតផងព្រមទាំងបានធ្វើរបងព័ទ្ធជុំវិញដីនេះ ស្រាប់តែ ឈ្មោះ កេត ផាន់ណា មកហាមឃាត់មិនឱ្យធ្វើ ហើយបច្ចុប្បន្នឈ្មោះនេះកំពុងរំលោភកាន់កាប់លើដីរបស់ខ្លួនដោយបំពាន ។

តាមបណ្តឹងតបចុះថ្ងៃទី ២៥-០២-២០០០ របស់ចុងចម្លើយឈ្មោះ កេត ផាន់ណា បានប្តឹងថា ខ្លួនសុំទាមទារយកដីរបស់ខ្លួនវិញដែលមានទទឹង ៨ម គុណ ២៩ម ដោយអាងហេតុថា : កាលពីថ្ងៃទី ០៣-០២-២០០០ ឈ្មោះ ហ៊ុយ ហ៊ាង បានបញ្ជាឱ្យកម្មករពានាក់ វាស់កាត់យកដីរបស់ខ្លួនទំហំទទឹង ៨ម បណ្តោយចាប់ពីក្រោយផ្ទះ ឃឹម ផង់ ដល់របងតាជឹម ហើយដាំបង្គោលរបងស៊ីម៉ង់ស្រេចតែអំពើចិត្ត ។ ពេលនោះខ្លួនបានឃាត់ដែរតែ ហ៊ុយ ហ៊ាង បានអះអាងថា ដីនេះខ្លួនទិញពីឈ្មោះ ឃឹម ផង់ ដោយមានរដ្ឋអំណាចមូលដ្ឋានទទួលស្គាល់ត្រឹមត្រូវ ហេតុនេះទើបខ្លួនមិនសុខចិត្តក៏ប្តឹងទាមទារដីនេះពីឈ្មោះ ហ៊ុយ ហ៊ាង វិញ និង ជម្ងឺចិត្តផងដែរ ព្រោះថាដីនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ ១៩៧៩មកម្ល៉េះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣៧"ជ" ចុះថ្ងៃទី ១០-៧-២០០០ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ :

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ១៨-០២-២០០០ របស់ដើមចោទឈ្មោះ ហ៊ុយ ហ៊ាង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងតបចុះថ្ងៃទី ២៥-០២-២០០០ របស់ឈ្មោះ កេត ផាន់ណា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយគតិច្បាប់ ។

៣-ប្រគល់ដីទំហំ ៨ម គុណ ៦,៤០ម មានព្រំប្រទល់ខាងជើងទល់នឹងរបងថ្ម ជួប ជឹម ខាងត្បូងទល់នឹងផ្លូវទំនប់បឹងទំពុន ខាងកើតទល់នឹងដី គួយ គុណ ខាងលិចទល់នឹងដី សៀង សុផា ឱ្យទៅឈ្មោះ ហ៊ុយ ហ៊ាង ចាប់ពីថ្ងៃសាលក្រមស្ថាពរតទៅ ។

៤-បង្គាប់ឱ្យឈ្មោះ កេត ផាន់ណា សងជម្ងឺចិត្តចំនួន ២.០០០ដុល្លា ឱ្យទៅឈ្មោះ ហ៊យ ហ៊ាង ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៥-រំបអូសប្រាក់ប្រដាប់ក្តីចំនួន ១៤.០០០៛ ពីដើមចោទឈ្មោះ ហ៊យ ហ៊ាង និង ចុងចម្លើយឈ្មោះ កេត ផាន់ណា ដែលបានបង់ទុកជាមុនស្រេច ។ បង្គាប់ឱ្យឈ្មោះ កេត ផាន់ណា សងប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛ ទៅដើម ចោទវិញពេលសាលក្រមចូលជាស្ថាពរ ។

បង្គាប់ឱ្យឈ្មោះ កេត ផាន់ណា បង់ពន្ធសមាមាត្រចំនួន ១% គិតពីតម្លៃដី ២.៥៦០ដុល្លា និង ប្រាក់សំណងជម្ងឺចិត្តចំនួន ២.០០០ ដុល្លាអាមេរិក ។ ប្រាក់ពន្ធសមាមាត្រ ១% នេះត្រូវបង់ចូលថវិការដ្ឋចំនួន ៨០% និង វង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន ២០% ពេលសាលក្រមចូលជាស្ថាពរ ។

៦- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគី បើភាគីណាពុំសុខចិត្ត នឹង សាលក្រមនេះមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ០២ ខែ ចាប់ពីថ្ងៃប្រកាសសាលក្រម ។

សាលក្រមនេះត្រូវបានអ្នកស្រី កេត ផាន់ណា ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ២២ ចុះថ្ងៃទី ១៤-៧-២០០០ គ្រប់ចំនុចសាលក្រមទាំងមូល ។

បានឃើញសាលដីកាលេខ ៥៩ "ឈ" ចុះថ្ងៃទី ២៨-១២-២០០០ របស់សាលាឧទ្ធរណ៍ ដែលសំរេចដូចតទៅ :-

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី ១៤-៧-២០០០ របស់ឈ្មោះ កេត ផាន់ណា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៣៧ "ជ" ចុះថ្ងៃទី ១០-៧-២០០០ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-កែប្រែចំណុចទី ៤ ក្រោយពាក្យ "ជាស្ថាពរ" ដោយបន្ថែមថា "ការប្តឹងទារលើសពីនេះបដិសេធចោល" ។

៤-បដិសេធសេចក្តីសំរេចលេខ ១២១ស.ស ចុះថ្ងៃទី ០៣-៣-៩៣ របស់គណៈកម្មាធិការប្រជាជនក្រុងភ្នំពេញចោលជាអសារបង់ ។

៥-រំបអូសប្រាក់ប្រដាប់ក្តីដែលនាង កេត ផាន់ណា បានបង់រួចហើយគឺ ពន្ធហ្វើង និង ពន្ធចុះបញ្ជីក្តី ២.៥៥០៛ វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និង ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៦-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សាលដីកានេះត្រូវបានអ្នកស្រី កេត ផាន់ណា ប្តឹងសាទុក្ខតាមបណ្តឹងលេខ ០៨ ចុះថ្ងៃទី ១០-០១-២០០១ មិនសុខចិត្តនឹងសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥៦ ចុះថ្ងៃទី ១៤-៣-២០០២ របស់តុលាការកំពូល ដែលសំរេចដូចតទៅ :-

១-ទទួលបណ្តឹងសាទុក្ខលេខ ០៨ ចុះថ្ងៃទី ១០-០១-២០០១ របស់អ្នកស្រី កេត ផាន់ណា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៥៩"ឈ" ចុះថ្ងៃទី ២៨-១២-២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៤៦ ចុះថ្ងៃទី ២១-៥-២០០១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោក ហ៊ុយ ហ៊ាង បានបង់គឺ :-

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊្វីងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩០០០៛ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១៤-៣-២០០២ ។

បានឃើញសាលដីកាលេខ ៩៦"ត"ចុះថ្ងៃទី ១២-៦-២០០៣ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីលើកទី ២ មានខ្លឹមសារដូចតទៅ :-

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណី ១៤៦ ចុះថ្ងៃទី ២១-៥-២០០១ តាមអំណាចសាលដីការដ្ឋប្បវេណី របស់តុលាការកំពូលលេខ ៥៦ ចុះថ្ងៃទី ១៤-៣-២០០២ ។

២-ប្រគល់ដីទំហំ ៨ម គុណ ៦,៤០ម ដែលមានព្រំប្រទល់ខាងជើងទល់របងថ្ម ជួប ជឹម ខាងត្បូងទល់ផ្លូវទំនប់បឹងទំពុន ខាងកើតទល់ដី គួយ គុណ ខាងលិចទល់ដី សៀង សុផា ស្ថិតនៅភូមិត្រពាំងជ្រៃ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឱ្យឈ្មោះ ហ៊ុយ ហ៊ាង កាន់កាប់ជាកម្មសិទ្ធិ ចាប់ពីសាលដីកាចូលស្ថាពរតទៅ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺៈ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊្វីង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង អាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ និង បង្គាប់ឱ្យ កេត ផាន់ណា បង់ពន្ធសមាមាត្រ ១% លើថ្លៃដីទំនាស់ ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី និង មេធាវីចុងចម្លើយ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សាលដីកានេះត្រូវបានអ្នកស្រី កេត ផាន់ណា ប្តឹងសាទុក្ខតាមបណ្តឹងលេខ ២៥៣ ចុះថ្ងៃទី ២៤-៦-២០០៣ របស់អ្នកស្រី កេត ផាន់ណា ត្រង់ចំណុចទី២ នៃសេចក្តីសំរេច ។

បានឃើញសាលដីការបៀបលេខ ៥៦ ចុះថ្ងៃទី ២១-៣-២០០៥ របស់តុលាការកំពូល ដែលសំរេចដូចតទៅ :

១-ចាត់របៀបឱ្យចៅក្រមជំនុំជំរះចុះពិនិត្យផល់ទីតាំងដីទំនាស់ ហើយក្នុងករណីចាំបាច់ ធ្វើការស៊ើបអង្កេតបន្ថែម ។

២-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០៥ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលាឧទ្ធរណ៍សំរេចសេចក្តីលើកទី២មកនេះពុំត្រឹមត្រូវទេ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី កេត ផាន់ណា នាពេលសវនាការថា :- សាលាឧទ្ធរណ៍ មិនបានពិនិត្យលើផ្ទៃដីរបស់ខ្លួនឱ្យបានច្បាស់ ដីនេះខ្លួនកាន់កាប់តាំងពី ១៩៧៩ ។

ដីនេះ ឃឹម ផង់ ខ្ចីខ្លួននៅចុងឆ្នាំ ៨៤-៨៥ ដោយមានលិខិតខ្ចីត្រឹមត្រូវ ហើយលួចលក់ឱ្យ ហ៊ាយ ហ៊ាង ដូច្នេះខ្លួនត្រូវតែទាមទារដីនេះវិញទាំងមូល ។ បច្ចុប្បន្នខ្លួនរស់នៅលើដីរបស់បងខ្លួន ឯដីខ្លួនត្រូវគេយក ដូច្នេះតើខ្លួនបានអីនៅ ។

ពេលទិញ ហ៊ាយ ហ៊ាង ក៏គួរតែសួរអ្នកជាប់ព្រំដែរ ។

សំណូមពរសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង ព្រោះខ្លួនគ្មានដីណាផ្សេងពីនេះទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ហ៊ាយ ហ៊ាង នាពេលសវនាការថា :-ខ្លួនមានលិខិតស្នាមត្រឹមត្រូវ គឺមានបង្កាន់ដៃទទួលពាក្យសុំកាន់កាប់របស់ ឃឹម ផង់ តាំងពី ៨៥ គឺធ្វើមុន កេត ផាន់ណា កន្លះឆ្នាំឯណោះ ។ ដីនេះមានទទឹង ៨ម គុណ ៣០ម ដោយមានព្រំប្រទល់ត្រឹមត្រូវទាំងអស់ ។

សំណូមពរសុំកាន់កាប់ដីនេះ ព្រោះដីនេះខ្លួនទិញពិតប្រាកដ មិនបានលួចទិញទេ ។

ដីនេះខ្លួនជូនតម្លៃ ១៣.០០០ដុល្លាអាមេរិក ។

អ្នកស្រី កេត ផាន់ណា តប : ខ្លួនទទួលយកមិនបានទេ ខ្លួនចុះថ្លៃឱ្យ ១.០០០ដុល្លាអាមេរិក នៅសល់ ៣៩.០០០ដុល្លាអាមេរិក ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក កែវ យ៉ា មេធាវីការពារឱ្យចុងចម្លើយថា: ដីដែលគាត់ទិញមានទំហំ ៨ ម គុណ ១០ម ទេ តែក្នុងសវនាការលោកថា ៨ម គុណ ៣០ម តើរឿងនេះយ៉ាងម៉េច ?

លោក ហ៊ាយ ហ៊ាង ឆ្លើយ : ដីនេះកាត់ចំណីទំនប់ហើយ ។

អ្នកស្រី កេត ផាន់ណា តប : បើកាត់ចំណីទំនប់ហើយ ផ្ទះ ឃឹម ផង់ ក៏គ្មានដែរ ព្រោះដីខាងក្រោយជារបស់ខ្លួន ។

លោកមេធាវី កែវ យ៉ា បន្ត : ឃឹម ផង់ មិនបានប្តឹងនឹងសេចក្តីសំរេចរបស់តុលាការក្រុងទេ ។ ឯរដ្ឋអំណាចឃុំឃាត់ ឃឹម ផង់ មិនឱ្យមានការបញ្ចាំ តែក្រោយមកបែរជាទទួលស្គាល់ការលក់របស់ ឃឹម ផង់ ទៅឱ្យ ហ៊ាយ ហ៊ាង ទៅវិញ ។

សំណូមពរ សុំប្រគល់ដីទំនាស់មកឱ្យកូនក្តីខ្លួនកាន់កាប់បន្ត ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ហាក់ សៀកលី មេធាវីការពារឱ្យដើមចោទថា: ការកាន់កាប់របស់ ឃឹម ផង់ គឺដោយសុចរិត និង ស្របតាមច្បាប់ភូមិបាល ។

ពេលដាក់ពាក្យសុំកាន់កាប់របស់អ្នកស្រី កេត ផាន់ណា គឺមានការជំទាស់ពីរដ្ឋអំណាចរួចទៅហើយ ។ ការសំរេចរបស់សាលាក្រុង អ្នកស្រី ឃឹម ផង់ បានប្តឹងរហូត គឺបានប្តឹងតវ៉ាទៅក្រុមប្រឹក្សារដ្ឋមន្ត្រី ។

សំណូមពរ សុំតុលាការមេត្តាសំរេចប្រគល់ដីឱ្យមកកូនក្តីលោកកាន់កាប់គ្រប់គ្រងបន្ត ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៩៣ ចុះថ្ងៃទី ២៤-៦-២០០៣ របស់អ្នកស្រី កេត ផាន់ណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់ សាលាជំរះក្តី និង មាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអាចអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដី ៨ម គុណ ៦.៤ម ឱ្យទៅលោក ហ៊ាយ ហ៊ាង ដោយសំអាងហេតុថាដីនេះត្រូវបានកាន់កាប់ដោយម្ចាស់ដីដើមឈ្មោះ ឃឹម ផង់ បានកាន់កាប់តាំងពីឆ្នាំ ១៩៨៤ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះពុំមានភស្តុតាងណាបញ្ជាក់ថាម្ចាស់ដីដើមឈ្មោះ ឃឹម ផង់ បានកាន់កាប់ និង អាស្រ័យផលលើដីទំនាស់នេះទាំងមូលទេ ។

-យល់ឃើញថា ម្ចាស់ដីដើមអ្នកស្រី ឃឹម ផង់ ពិ តជាបានកាន់កាប់ និង សង់ផ្ទះនៅផ្នែកខាងមុខ នៃដីនេះតាំងពីឆ្នាំ ១៩៨៤ ហើយការដែលអ្នកស្រី កេត ផាន់ណា អះអាងថាអ្នកស្រី ឃឹម ផង់ បានខ្ចីអ្នកស្រីនោះពុំមានភស្តុតាងណាបញ្ជាក់ទេ ហើយទោះបីមានការខ្ចីដីស្នាក់នៅមែនក៏ដោយក៏អ្នកស្រីថ្មោះសិទ្ធិក្នុងការទាមទារទៀតហើយតាមការកំណត់នៃមាត្រា ២៥ នៃ ក្រឹត្យច្បាប់លេខ ៣៨ ក្រ-ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

-យល់ឃើញថា គ្រប់អាជ្ញាធរមូលដ្ឋានសុទ្ធតែបញ្ជាក់ថាដីទំនាស់នេះជាដីរបស់ ឃឹម ផង់ ប៉ុន្តែមូលដ្ឋានអំពីការកាន់កាប់នេះពុំទាន់ច្បាស់លាស់នៅឡើយ ។

-យល់ឃើញថា មូលដ្ឋាននៃការកាន់កាប់របស់អ្នកស្រី កេត ផាន់ណា ក៏មានលក្ខណៈមិនច្បាស់លាស់ដែរ ពីព្រោះដីនេះជាដីទំនាបពុំអាចបង្កបង្កើនផលបានទេ ហើយតាមការចុះពិនិត្យដល់ទីកន្លែងចៅក្រមតុលាការកំពូល ពិនិត្យឃើញថាពុំមានដំណាំណាមួយគួរឱ្យកត់សំគាល់ដែរ ។ ប៉ុន្តែមានមូលដ្ឋានថាអ្នកស្រី កេត ផាន់ណា បានហួងហែងដីនេះរហូតមក ។

-យល់ឃើញថា លោក ហ៊ាយ ហ៊ាង បានទិញដីពីអ្នកស្រី ឃឹម ផង់ តាមលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ០៤-៨-៩៩ ដីមានទំហំ ៨ម គុណ ១០ម ដូចនេះគប្បីតុលាការកំពូលពិចារណា និង សំរេចពីសិទ្ធិនេះ ដើម្បីជាប្រយោជន៍ដល់គូភាគី ។

-យល់ឃើញថា កិរិយាកាន់កាប់របស់គូភាគីដែលបានធ្វើឡើងចំពោះដីទំនាស់ស្ថិតក្នុងសភាពព្រលាំ ដែលមិនអាចកំណត់បានថាភាគីណាមួយបានធ្វើឡើងដោយដាច់មុខនោះឡើយ ដូចនេះគប្បីសម្រេចបែងចែកឱ្យគូភាគីតាមចំណែកដែលខ្លួនធ្លាប់ហូងហែង និង តាមកិច្ចសន្យាដែលបានធ្វើដោយកំណត់ទីតាំង និង ទំហំចំណែកនៃដីទំនាស់នៅលើគំនូសប្លង់ ចុះថ្ងៃទី ២២-៧-២០០៥ របស់ចៅក្រមប្រឹក្សាតុលាការកំពូល ដែលត្រូវកំណត់ដូចខាងក្រោមនេះ :-

+ពីចំណុច A ទៅ B ជាជ្រុងផ្នែកខាងក្រោយ(ខាងជើង)នៃ ដីទំនាស់ជាប់ព្រំជាមួយដីឈ្មោះ ជួប ជឹម ។

+ពីចំណុច A ទៅ D ជាជ្រុងផ្នែកខាងលិច នៃ ដីទំនាស់ជាប់ព្រំជាមួយដីឈ្មោះ ហ៊ុយ ហ៊ាង ដែលទិញពីសៀង សុផា ។

+ពីចំណុច B ទៅ C ជាជ្រុងផ្នែកខាងកើត នៃដីទំនាស់ជាប់ព្រំជាមួយដីឈ្មោះ កេត ប៉ាក់មុន ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៩៦"ត" ចុះថ្ងៃទី ១២-៦-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះមានការខុសឆ្គងទាំងតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី

១-ទទួលបណ្ដឹងសាទុក្ខលេខ ២៩៣ ចុះថ្ងៃទី ២៤-៦-២០០៣ របស់អ្នកស្រី កេត ផាន់ណា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៩៦"ត"ចុះថ្ងៃទី ១២-៦-២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-ប្រគល់ដីទំនាស់ :

**ក-ដី ABCDAជាផ្នែកខាងក្រោយ នៃ ដីទំនាស់ ដោយចាប់គិតពីព្រំដីជាមួយ ឈ្មោះ ជួប ជឹម ដែលមានជ្រុង AB = CD = ៨.១០ម និង AD = BC = ១៦ម តាមគំនូសប្លង់ចុះថ្ងៃទី ២២-៧-២០០៥ របស់ចៅក្រមប្រឹក្សានៃតុលាការកំពូល ត្រូវប្រគល់ឱ្យអ្នកស្រី កេត ផាន់ណា គ្រប់គ្រងតាមច្បាប់ និង តាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច ។**

**ខ-ដីផ្នែកខាងមុខដែលនៅសល់ពីដី ABCDA ដោយវាស់ចាប់គិតពីជ្រុង CDមកត្រូវប្រគល់ឱ្យលោក ហ៊ុយ ហ៊ាង គ្រប់គ្រងតាមច្បាប់ និង តាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច ។**

**៤-រំបអូសប្រាក់ប្រដាប់ក្ដីដែលអ្នកស្រី កេត ផាន់ណា បានបង់នៅតុលាការកំពូល ចំនួន ១៩.០០០៛ គឺ :-**

**-ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វឹងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .**

**-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩០០០៛ ។**

**+តម្រូវឱ្យលោក ហ៊ុយ ហ៊ាង សងប្រាក់ចំនួន ១៩.០០០៛នេះទៅអ្នកស្រី កេត ផាន់ណា វិញ ។**

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ។